# ច្បាប់

# ស្តីពី

# ការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥

# ភាគទី ១

# បទបញ្ញត្តិនៃច្បាប់ហិរញ្ញវត្ថុកែតម្រូវ

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.-**

មាត្រា ១ មាត្រា ២ មាត្រា ៤ និង មាត្រា ៦ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយបទបញ្ញត្តិទាំងឡាយដូចតទៅ ៖

មាត្រា ១(ថ្មី) - នៅតែត្រូវបានអនុញ្ញាតសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ អោយប្រមូលជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋនូវ ពន្ធដារ វិភាគទាន ផលិតផលនិងផលទុន ព្រមទាំងការធ្វើអោយសំរេចនូវអំណោយមូលនិធិបដិភាគនិងធនធានបានមកពីការខ្ចីបុល ដែលបានគ្រោងទុកនៅ តារាង "ក" ដូចមានបញ្ជាក់នៅភាគទី ២ នៃច្បាប់នេះ មានចំនួនទឹកប្រាក់សរុប.................................១.២៨៣.០០០ លានរៀល និងត្រូវបែងចែកដូចតទៅ ៖

- ចំណូលជាប្រចាំ ................................................ ៦៩៤.៤០០ លានរៀល
- ចំណូលជាមូលធន ............................................ ៥៨៨.៦០០ លានរៀល

មាត្រា ២(ថ្មី) - ចំនួនទឹកប្រាក់ជាអតិបរិមានៃឥណទាន សំរាប់ចំណាយក្នុងថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ត្រូវបានកំណត់ស្មើនឹង ................................ ១.២៨៣.០០០ លានរៀល និងត្រូវបែងចែកដូចតទៅ ៖

- ចំណាយជាប្រចាំ ................................................ ៧៩២.២០០ លានរៀល
- ចំណាយជាមូលធន ............................................ ៤៩០.៨០០ លានរៀល

មាត្រា ៤(ថ្មី) - ចំនួនទឹកប្រាក់ជាអតិបរិមានៃឥណទាន សំរាប់ចំណាយជាប្រចាំរបស់រដ្ឋសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥ ត្រូវបានកំណត់ស្មើនឹង .................................... ៧៩២.២០០ លានរៀល ឥណទាននេះត្រូវបានបែងចែកទៅតាមក្រសួងនីមួយៗ និងស្ថាប័នសាធារណៈប្រហាក់ប្រហែលនីមួយៗ និងតាមប្រភេទដូចមានចែងក្នុងតារាង "ខ" ភាគទី ២នៃច្បាប់ ។

មាត្រា ៦(ថ្មី) - ចំនួនទឹកប្រាក់ចំណាយជាមូលធននៃថវិការដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ត្រូវបានកំណត់ស្មើនឹង .................................................... ៤៩០.៨០០ លានរៀល ។ វិនិយោគសាធារណៈ ដែលរ៉ាប់រងដោយចំណាយជាមូលធន ត្រូវបានបែងចែកតាមប្រភពនៃហិរញ្ញប្បទានដូចតទៅ ៖

- វិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស .................... ៦៦.៤០០ លានរៀល

- វិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស..................... ៣៧២.១០០ លានរៀល

ដោយអនុលោមទៅនឹងបទបញ្ញត្តិនៃមាត្រា ១៥ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដូចបានបញ្ជាក់ខាងលើ វិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ គឺជា "ជំនួយគំរោងការ" ។ ចំណូលដែលបានមកពីហិរញ្ញប្បទានផ្ទាល់របស់អ្នកផ្ដល់មូលនិធិសំរាប់វិនិយោគសាធារណៈ ពុំឆ្លងកាត់ធនាគារជាតិឡើយ ។ ចំណាយសំរាប់វិនិយោគប្រភេទនេះ មិនរាប់ចូលជាការអនុញ្ញាតចំណាយសំរាប់អាណាប័កទេ ហើយវាមានលក្ខណៈគ្រោងទុកជាតំណាងតែប៉ុណ្ណោះ ។

ក៏ប៉ុន្តែ វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស គឺជាឥណទានថវិកា ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាណាប័ក ដើម្បីសំរេចនូវគំរោងការរបស់ខ្លួន ។ ឥណទាននេះមានលក្ខណៈកំរិតកំណត់ ហើយត្រូវបានគ្រប់គ្រងក្នុងក្របខ័ណ្ឌរតនាគារជាតិ ។

ទាយជ្ជទានសំរាប់វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់និងឥណទានសំរាប់វិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្នុងប្រទេសនិងសំរាប់ចំណាយជាមូលធនផ្សេងៗទៀត ត្រូវបានបែងចែកតាមក្រសួង តាមស្ថាប័នសាធារណៈប្រហាក់ប្រហែល និងតាមជំពូកថវិកាដែលមានចែងក្នុងតារាង "ឃ" ដូចបានបញ្ជាក់នៅក្នុងភាគទី ២ នៃច្បាប់នេះ ។

## មាត្រា ២. -

ត្រូវបានយល់ព្រមការចុះកិច្ចសន្យាខ្ចីបុល ដោយរាជរដ្ឋាភិបាលកម្ពុជា ពីផ្នែកឯកជនក្រៅនិងក្នុងប្រទេស សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៤ និង ឆ្នាំ ១៩៩៥ ដែលមានទឹកប្រាក់

ចំនួន ........................................................ ៣៩,៦២៥ លានដុល្លារអាមេរិក

ស្មើនឹង ........................................................ ៩៨:៨៨៤ លានរៀល

ហើយត្រូវបែងចែកដូចតទៅ ៖

| ប្រភេទនៃការខ្ចីបុល | ពាន់ដុល្លារអាមេរិក | លានរៀល |
|---|---|---|
| សរុប | ៣៩.៦២៥,២ | ៩៨.៨៨៤,១ |
| ការខ្ចីបុលឯកជនក្រៅប្រទេស | ៣៦.៦២៥,២ | ៩១.១៩៥,១ |
| - ការខ្ចីបុលរយៈពេលមធ្យម (៥ឆ្នាំ) | ៣២.៩៣៧,៨ | ៨១.៧៤៤,៣ |
| + សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៤ | ១៦.៥២៤,៨ | ៤២.៣៥៣,១ |
| + សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ | ១៦.៤១៣,០ | ៣៩.៣៩១,២ |
| - ឥណទានអ្នកផ្គត់ផ្គង់ (២ឆ្នាំ:១៩៩៤) | ៣.៦៨៧,៤ | ៩.៤៥០,៨ |
| ការខ្ចីបុលឯកជនក្នុងប្រទេស (២ឆ្នាំ:១៩៩៥) | ៣.០០០,០ | ៧.៦៨៩,០ |

ទឹកប្រាក់នៃការខ្ចីបុលនេះមានចែងលើតារាង "ក" ដូចបានបញ្ជាក់នៅក្នុងភាគទី ២ នៃច្បាប់នេះ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ហើយក៏មានដូចគ្នាដែរនៅលើតារាង "ក" នៃច្បាប់ស្ដីពីការទូទាត់ថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៤ ។ ការរំលស់នៃការខ្ចីបុលនេះ មានចែងល្អើតារាង "ខ" ក្នុងភាគទី ២ នៃច្បាប់នេះ ។

# ជំពូកទី ២

## បទបញ្ញត្តិដែលទាក់ទងនឹងការខ្ចីបុល និង ការធានារបស់រដ្ឋ

## ផ្នែកទី ១

## ការខ្ចីបុលរបស់រដ្ឋ

**មាត្រា ៣.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់តាមការប្រទានសិទ្ធិជាលាយលក្ខណ៍អក្សរ របស់សម្តេចនាយករដ្ឋមន្ត្រីទាំងពីរនៃរាជរដ្ឋាភិបាល ក្នុងការចុះហត្ថលេខាលើការខ្ចីបុលជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋឬលើការធានារបស់រដ្ឋ ។

ក្នុងក្របខណ្ឌនេះ ទឹកប្រាក់ជាអតិបរិមាដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវអនុញ្ញាតអោយខ្ចីបុលមានកំរិតរហូតដល់ ១៥០.០០០.០០០ SDR (មួយរយហាសិបលាន អេសដេអ៊ែរ) សំរាប់ឆ្នាំ ១៩៩៥ ។

ការខ្ចីបុលដែលត្រូវចុះកិច្ចសន្យាក្នុងកំរិតខាងលើ ត្រូវមានលក្ខណៈជាការខ្ចីបុលសម្បទាន ដែលត្រូវសងវិញនិង ការប្រាក់អនុគ្រោះ ។ ប៉ុន្តែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការទាក់ទងជាមួយ ធនាគារជាតិនៃកម្ពុជា ត្រូវបានទទួលការអនុញ្ញាតអោយលក់ប័ណ្ណរតនាគារ ដើម្បីជាកំរៃសំរាប់បំពេញថវិកាជាបណ្តោះអាសន្នឬសំរាប់ដោះស្រាយតម្រូវការជាបន្ទាន់ខាងសាច់ប្រាក់ ។ លក្ខខណ្ឌនៃការលក់ប័ណ្ណរតនាគារនេះត្រូវកំណត់ដោយលិខិតបទដ្ឋានស្របច្បាប់ ។

ត្រូវហាមឃាត់សំរួបការគ្រប់គ្រងថវិកាឆ្នាំ ១៩៩៥ និងឆ្នាំ ១៩៩៦ នូវការខ្ចីបុល ឬការធានារបស់រដ្ឋតាមលក្ខខណ្ឌពាណិជ្ជកម្ម តែការហាមឃាត់នេះ មិនប៉ះពាល់ដល់បទបញ្ញត្តិនៃមាត្រា ២ ខាងលើនោះទេ ។

មិនអនុញ្ញាតអោយក្រសួងឬស្ថាប័នសាធារណៈចំណុះរដ្ឋណាមួយ មានសិទ្ធិចុះហត្ថលេខា ក្រោមរូបភាពបោះផ្សាយមូលប័ត្ររយៈពេលវែង មធ្យម ខ្លី ឬឥណទានអ្នកផ្គត់ផ្គង់ ឬចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចីបុល ឬការធានាកិច្ចសន្យាដែលបានចុះហត្ថលេខាយល់ព្រមដោយស្ថាប័នសាធារណៈឬឯកជន ឬចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសងបំណុលតាមកាលកំណត់ឬតាមឆ្នាំ ស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុ និងលក្ខខណ្ឌទាំងឡាយដែលច្បាប់នេះកំណត់នោះទេ ។

លក្ខខណ្ឌទាំងឡាយនៃកិច្ចប្រតិបត្តិការនីមួយៗ ត្រូវបានកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល យោងតាមរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

រាល់ការសំរេចលើកិច្ចព្រមព្រៀងស្តីពីការខ្ចីបុលនិងការធានារបស់រដ្ឋទៅតាមលក្ខខណ្ឌខាងលើ ត្រូវរាយការណ៍ជូនរដ្ឋសភានាសម័យប្រជុំបន្ទាប់ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តបទបញ្ញត្តិទាំងនេះ ជូនរដ្ឋសភារៀងរាល់ ៦ ខែម្តង ។

# ផ្នែកទី ២

## អំពីការចូលទុនរបស់រដ្ឋក្នុងសហគ្រាស

**មាត្រា ៤.-**

ការចូលទុនរបស់រដ្ឋដោយផ្ទាល់ក្នុងក្រុមហ៊ុនណាមួយ ក្រោមរូបភាពនៃទុនជាសាច់ប្រាក់ឬជាទ្រព្យសម្បត្តិ អាចធ្វើបានដោយរដ្ឋឬដោយស្ថាប័នសាធារណៈ ក្រោមចំណុះតែក្នុងកំរិតនៃឥណទានដែលត្រូវបានអនុញ្ញាតដោយច្បាប់ហិរញ្ញវត្ថុតែប៉ុណ្ណោះ ។

**មាត្រា ៥.-**

អនុញ្ញាតអោយរដ្ឋចូលទុនក្នុងក្រុមហ៊ុនចំរុះ ដែលមានឈ្មោះថា អាកាសចរណ៍ភូមិន្ទកម្ពុជាដោយមានភាគទុនជាសាច់ប្រាក់និងជាទ្រព្យសម្បត្តិ ។

# ជំពូកទី ៣

## អំពីការទទួលខុសត្រូវនៃអ្នកគ្រប់គ្រងប្រាក់កាសសាធារណៈ

**មាត្រា ៦.-**

ដោយអនុវត្តតាមបទបញ្ញត្តិនៃមាត្រា១៨ នៃច្បាប់ស្តីអំពីប្រពន្ធ័ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និង តាមមាត្រា ៣ នៃច្បាប់ហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ត្រូវបានចាត់ជាកំហុសមួយក្នុងការគ្រប់គ្រងដែលបានប្រព្រឹត្តចំពោះរដ្ឋ ៖

- រាល់អំពើដែលបានប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិ ដែលបានចែងក្នុងជំពូកទី ២ ខាងលើ
- រាល់អំពើដែលបណ្តាលអោយមានចំណាយលើសឥណទាននៃថវិកាដែលត្រូវបានអនុម័តដោយរដ្ឋសភា លើកលែងតែពីឥណទានដែលត្រូវបានទុកសំរាប់បើកផ្តល់ប្រាក់បៀវត្សនិងប្រាក់វិភាគទានសង្គម ដែលមានការពាក់ព័ន្ធ សេវានៃបំណុលនិងការទូទាត់ប្រាក់ដែលយល់ព្រមដោយរដ្ឋសភា ព្រមទាំងការបង់វិភាគទានចំពោះអង្គការអន្តរជាតិ ។
- រាល់អំពើដែលជាកម្មវត្ថុនាំអោយបង្កើនដោយចេតនាពិសេស នូវទឹកប្រាក់ឥណទាននៃថវិកាដែលបានទទួលការអនុញ្ញាតពីរដ្ឋសភា លើកលែងតែករណីដែលបានកំណត់ដោយច្បាប់និងបទបញ្ញាជាធរមាន និង ដោយអនុសញ្ញាអន្តរជាតិដែលរដ្ឋសភាបានអោយសច្ចាប័ន ។
- រាល់កំហុសធ្ងន់ដែលនាំអោយមានរង្វះខាតបង់ជាប្រាក់កាសដែលហិរញ្ញវត្ថុសាធារណៈទទួលបន្ទុក ។

_ ហើយជាទូទៅរាល់សកម្មភាពគ្រប់គ្រងកន្លងមក ដែលជាការប្រព្រឹត្តបទល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានដែលត្រូវអនុវត្តក្នុងការប្រមូលចំណូលនិងក្នុងការទូទាត់ចំណាយរបស់រដ្ឋ ។

**មាត្រា ៧._**

អាជ្ញាធរទាំងឡាយដែលមានឋានៈជាអាណាប័កឬអាណាប័កតាមការប្រទានសិទ្ធព្រមទាំងមន្ត្រីរាជការនិងភ្នាក់ងាររដ្ឋត្រូវទទួលខុសត្រូវដោយខ្លួនឯងលើការប្រព្រឹត្តបទល្មើសនឹងបទបញ្ញត្តិដែលមានចែងក្នុងជំពូកនេះ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តថវិកាជូនរដ្ឋសភារៀងរាល់ ៦ ខែម្តង ដោយយកចិត្តទុកដាក់ខ្ពស់លើលក្ខខណ្ឌទាំងឡាយនៃការអនុវត្តទៅតាមបទបញ្ញត្តិនៃថវិកា ព្រមទាំងច្បាប់ ព្រះរាជក្រឹត្យនិងបទបញ្ញត្តិទាំងនោះ ។

# ជំពូកទី ៤

## បទបញ្ញត្តិស្តីពីពន្ធនិងអាករ

### ផ្នែកទី ១

### បទបញ្ញត្តិស្តីពីទោសទណ្ឌទាក់ទិននឹងមូលដ្ឋានកំណត់ពន្ធនិងការត្រួតពិនិត្យ

**មាត្រា ៨._**

លើកលែងតែពន្ធប្រថាប់ត្រា ពន្ធតែមប្រ៊ិ៍ ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ការមិនបានបង់ ការបង់មិនគ្រប់ ឬការបង់យឺតនូវប្រភេទពន្ធឬអាករដែលប្រមូលដោយនាយកដ្ឋានពន្ធដារត្រូវបង់បន្ថែមនូវការប្រាក់យឺតយ៉ាវដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀត ។

**មាត្រា ៩._**

អត្រាការប្រាក់យឺតយ៉ាវមានចំនួន ២% ក្នុងមួយខែ ដោយគិតលើចំនួនទឹកប្រាក់ពន្ធដែលអ្នកជាប់ពន្ធត្រូវបង់បន្ថែមឬលើចំនួនប្រាក់ពន្ធបង់អោយយឺតយ៉ាវ ។

**មាត្រា ១០._**

ការប្រាក់យឺតយ៉ាវត្រូវគិតចាប់ពីថ្ងៃទី ០១ នៃខែបន្ទាប់ដែលជាខែត្រូវបង់ពន្ធ ។ ចំពោះពន្ធលើប្រាក់ចំណេញ ដែលត្រូវបានបង្កើតឡើងតាមលក្ខខណ្ឌកំណត់ក្នុងមាត្រា ២១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ចំណុចផ្តើមនៃការគិតការប្រាក់យឺតយ៉ាវគឺនៅថ្ងៃទី ០១ នៃខែបន្ទាប់ ដែលជាខែចុងរយៈពេលកំណត់សំរាប់ការដាក់លិខិតប្រកាសលទ្ធផលប្រចាំឆ្នាំ ។

## មាត្រា ១១._

ការគិតគូរការប្រាក់យឺតយ៉ាវត្រូវឈប់គិតឬមួយនៅថ្ងៃចុងក្រោយនៃខែ ដែលបានផ្ញើលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញឬមួយនៅថ្ងៃចុងក្រោយនៃខែដែលបានដាក់លិខិតប្រកាសពន្ធ ។

## មាត្រា ១២._

១_ ក្នុងរយៈពេលកំណត់ ការមិនបានដាក់លិខិតប្រកាសពន្ធដែលមានការបញ្ជាក់នូវចំណែកទុកសំរាប់កំណត់ឬគណនាប្រាក់ពន្ធឬអាករណាមួយ ដែលប្រមូលដោយនាយកដ្ឋានពន្ធដារនោះ ចំនួនប្រាក់ពន្ធដែលបានមកពីលិខិតប្រកាសពន្ធដែលដាក់យឺតយ៉ាវ ត្រូវបូកបន្ថែមលើការប្រាក់យឺតយ៉ាវ ដូចមានចែងក្នុងមាត្រា ៩ ចំនួន ១០% ទៀតនៃចំនួនប្រាក់ពន្ធ ។

២_ ការបន្ថែមចំពោះចំណុច ១ ត្រូវឡើងដល់ :

- ២៥% _កាលបើឯកសារបានដាក់ហួសរយៈពេលកំណត់ ១៥ថ្ងៃ បន្ទាប់ពីបានទទួលលិខិតរំលឹកដែលបញ្ជាក់ពីកាតព្វកិច្ចត្រូវបំពេញក្នុងរយៈពេលនេះ
- ៥០% ប្រសិនបើពុំបានដាក់ឯកសារណាមួយ ។

## មាត្រា ១៣._

ក្នុងករណីដែលលិខិតប្រកាសបង្ហាញអោយឃើញថា មូលដ្ឋានកំណត់ពន្ធឬចំណែកសំរាប់គណនាប្រាក់ពន្ធមានលក្ខណៈមិនគ្រប់គ្រាន់ មិនពិតប្រាកដ ឬមិនពេញលេញដែលកើតឡើងដោយអចេតនានោះ ចំនួនប្រាក់ពន្ធត្រូវបង់បន្ថែមដោយអ្នកជាប់ពន្ធ ត្រូវបូកបន្ថែមនូវការប្រាក់យឺតយ៉ាវដូចមានចែងក្នុងមាត្រា ៨ និងមាត្រា ៩ ។ ចំនួនប្រាក់បន្ថែមនេះត្រូវឡើងដល់ ៤០% បន្ថែមលើការប្រាក់យឺតយ៉ាវ ប្រសិនបើកំហុសខាងលើនេះត្រូវបានប្រព្រឹត្តដោយចេតនា ។

## មាត្រា ១៤._

កាលបើអ្នកជាប់ពន្ធបានបង្ហាញអោយពីង ដោយការកត់ត្រាយ៉ាងច្បាស់លាស់លើលិខិតប្រកាសពន្ធ លើលិខិតស្នាមឬលើលិខិតដែលជាឧបសម្ព័ន្ធភ្ជាប់ជាមួយនូវមូលហេតុខាងផ្លូវច្បាប់ ឬខាងហេតុការណ៍ដែលអ្នកជាប់ពន្ធមិនបានកត់ត្រានូវចំណែកសំរាប់កំណត់ពន្ធទាំងអស់ឬចំណែកណាមួយឬក៏បានផ្តល់ចំពោះចំណែកទាំងនេះ នូវការបញ្ជាក់ដែលនាំអោយមានការកំណត់ពន្ធដោយបន្ធូរបន្ថយ ឬការកាត់កងពន្ធដែលត្រូវបានទទួលស្គាល់ពេលក្រោយថាមិនសមហេតុផលនោះ ការកំណត់ពន្ធឡើងវិញចំពោះករណីទាំងនេះ មិននាំអោយមានការអនុវត្តនូវការបង់ការប្រាក់យឺតយ៉ាវ ដូចមានចែងក្នុងមាត្រា ៨ និងមាត្រា ៩ ឡើយ ។

## មាត្រា ១៥._

ការប្រាក់យឺតយ៉ាវនិងប្រាក់បន្ថែមមិនត្រូវអនុវត្តទេ កាលបើការខ្វះខាតអំពីតួលេខប្រកាសពន្ធមិនលើសពី ១ភាគ១០ នៃមូលដ្ឋានកំណត់ពន្ធ បន្ទាប់ពីមានការកំណត់ពន្ធឡើងវិញ ។

មាត្រា ១៦.-

ត្រូវបានលុបចោលដោយបទបញ្ញត្តិច្បាប់នេះនូវ ៖

- មាត្រា ១៤ នៃអនុក្រឹត្យលេខ ០៧ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩១ ស្តីពីពន្ធសត្តឃាត
- មាត្រា ២៣ និងមាត្រា ២៤ ជំពូក ៥ នៃក្រឹត្យច្បាប់លេខ ២២ក្រច ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៩ ស្តីពីពន្ធប៉ាតង់
- មាត្រា ១៨ និងមាត្រា ១៩ នៃក្រឹត្យច្បាប់លេខ ២៤ ក្រច ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៩ ស្តីពីពន្ធលើទំនិញក្នុងប្រទេស
- មាត្រា ៥៧ មាត្រា ៥៩ និង ចំណុច ១ នៃមាត្រា ៦០ នៃច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។

## ផ្នែកទី ២

## បទបញ្ញត្តិស្តីពីការកែប្រែពន្ធលើទំនិញក្នុងប្រទេស ជាអាករពិសេសលើទំនិញមួយចំនួន

មាត្រា ១៧.-

ចាប់ពីថ្ងៃប្រកាសអោយប្រើច្បាប់នេះ ពន្ធលើទំនិញក្នុងប្រទេសដែលបានបង្កើតឡើងដោយក្រឹត្យច្បាប់លេខ ២៤ក្រច ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៩ ត្រូវហៅថា " អាករពិសេសលើទំនិញមួយចំនួន " វិញ ដូចមានចែងក្នុងផ្នែកទី ២ ជំពូកទី ៤ នៃច្បាប់នេះ ។

មាត្រា ១៨.-

អត្រាអាករពិសេសលើទំនិញមួយចំនួន ដែលពីមុនឡើងដល់ ៥០% ទៅតាមក្រឹត្យច្បាប់ដូចពោលខាងលើ ត្រូវបន្ថយអោយមកនៅត្រឹមអត្រាពីរដូចតទៅ

- ២០% សំរាប់គ្រប់ផលិតផលតេលសិលា
- ១០% សំរាប់គ្រប់ផលិតផលផ្សេងទៀត ។

មាត្រា ១៩.-

ត្រូវជាប់អាករពិសេសលើទំនិញមួយចំនួន ទោះបីនាំចូលឬផលិតនៅព្រះរាជាណាចក្រកម្ពុជាក៏ដោយនូវ ៖

១- ផលិតផលតេលសិលា

- ប្រេងសាំងស៊ុបពែរ ឬធម្មតា សំរាប់យានយន្ត
- ប្រេងរំអិល

២_ ភេសជ្ជៈ :-

_ ទឹកមានជាតិឧស្ម័ន មានដាក់ស្ករ ឬក៏សារជាតិផ្អែមផ្សេងទៀត ឬគ្រឿងក្រអូបនិងភេសជ្ជៈឯទៀតដែលគ្មានជាតិសុរា លើកលែងតែទឹកនិងទឹកមីណេរ៉ាល់ ហើយនិងទឹកដមផ្លែឈើ ឬ ទឹកដមបន្លែ ។

- ស្រាបៀរ
- ស្រាទំពាំងបាយជូរស្រស់ រួមទាំងស្រាទំពាំងបាយជូរដែលមានបន្ថែមជាតិសុរា
- ស្រាវែមុតនិងស្រាទំពាំងបាយជូរស្រស់ផ្សេងទៀតធ្វើពីរុក្ខជាតិនិងសារជាតិក្រអូប
- ភេសជ្ជៈមើយផ្សេងទៀត

_ អាល់កុលអេទីលីកសុទ្ធដែលមានកំរិតជាតិសុរាក្នុងឯកតាចំណុះពី៨០% នៃចំណុះ ឬលើសពីនេះ និងអាល់កុលអេទីលីក ហើយនិងភេសជ្ជៈមានជាតិសុរាដែលបាត់បង់កំរិតសុរាដើមរបស់វា ។

_ អាល់កុលអេទីលីកបាត់បង់ធាតុសុទ្ធ ដែលមានកំរិតជាតិសុរាក្នុងឯកតាចំណុះ ៨០% នៃចំណុះ និងភេសជ្ជៈមានជាតិសុរា ភេសជ្ជៈស្រវឹងផ្សេងៗទៀត ការរៀបចំកែច្នៃសុរាធ្វើក្នុងប្រភេទដែលប្រើសំរាប់ផលិតភេសជ្ជៈ ។

៣_ បារី បារីស៊ីហ្គា គ្រប់ប្រភេទ ។

## មាត្រា ២០._

ផលិតផលដូចតទៅ លែងត្រូវជាប់អាករពិសេសលើទំនិញមួយចំនួនទៀតហើយ

- ថ្នាំជក់មិនកែច្នៃ
- កាហ្វេ
- គ្រាប់ឈូក

## មាត្រា ២១._

មូលដ្ឋានកំណត់អាករពិសេសលើទំនិញមួយចំនួន ចំពោះ :

១_ ផលិតផលនាំចូល គឺតំលៃក្នុងតារាងផលិតផលនាំចូលបូកបន្ថែមពន្ធនិងអាករ ដែលត្រូវបង់នាពេលនាំចូល លើកលែងតែអាករពិសេសខ្លួនឯងនេះ និងអាករប្រើប្រាស់ដែលត្រូវបង់នាពេលនាំចូល ។

២_ ផលិតផលធ្វើនៅព្រះរាជាណាចក្រកម្ពុជា គឺថ្លៃលក់កត់ត្រាក្នុងវិក័យប័ត្ររបស់អ្នកធ្វើដែលគិតបញ្ចូលទាំងសោហ៊ុយនិងអាករគ្រប់មុខ លើកលែងតែអាករពិសេសខ្លួនឯងនេះ និងអាករលើផលរបរ ។

## មាត្រា ២២._

ត្រូវជាប់អាករពិសេសលើទំនិញមួយចំនួនដែលបានចែងក្នុងមាត្រា ១៩ ៖

១_ ចំពោះទំនិញនាំចូល គឺគ្រប់ការដាក់ទំនិញអោយប្រើប្រាស់នៅលើដែនដីនៃប្រទេសជាតិទៅតាមន័យនៃពាក្យរបស់គយ ។

២_ ចំពោះទំនិញផលិតនៅព្រះរាជាណាចក្រកម្ពុជា គឺគ្រប់ការប្រគល់ទំនិញ ដោយគិតទាំងការប្រគល់ឱ្យដោយឥតយកថ្លៃដែលបានធ្វើឡើងតាមផ្លូវច្បាប់ ឬតាមហេតុការណ៍ពិត នៅលើដែនដីនៃប្រទេសជាតិ ។

ដោយឡែកត្រូវជាប់អាករពិសេសលើទំនិញមួយចំនួនផងដែរ នូវទំនិញដែលអ្នកធ្វើឬផលិតករកាត់យកសំរាប់តម្រូវការផ្ទាល់ខ្លួន សំរាប់តម្រូវការរបស់បុគ្គលិកឬសំរាប់តម្រូវការរបស់គតិយជន ។

## មាត្រា ២៣._

អាករពិសេសលើទំនិញមួយចំនួន ត្រូវបង់ដោយ :

១_ អ្នកនាំចូលឬអ្នកកាន់កាប់ទំនិញនៅព្រះរាជាណាចក្រកម្ពុជា ចំពោះទំនិញដែលមានដើមកំណើតពីក្រៅ ។

២_ ផលិតករឬអ្នកធ្វើ ចំពោះទំនិញផលិតឬធ្វើនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## មាត្រា ២៤._

អ្នកជាប់អាករពិសេសលើទំនិញមួយចំនួន ត្រូវកាន់បញ្ជីពិសេសមួយដែលបង្ហាញឱ្យឃើញច្បាស់នូវប្រភេទ បរិមាណ គុណភាព តម្លៃ ៖

១_ ចំពោះការនាំចូល និងការបញ្ចូលផលិតផល ទោះបីផលិតផលទាំងនេះ មានដើមកំណើតពីណាក្តី :

- លេខនិងកាលបរិច្ឆេទនៃប្រតិវេទន៍នាំចូល ឈ្មោះការិយាល័យគយដែលយកទំនិញចេញ កាលបរិច្ឆេទទទួល
- បរិមាណ ទម្ងន់ និងប្រភេទនៃទំនិញនាំចូល
- តម្លៃកត់ត្រាក្នុងវិក័យបត្រនិងមូលដ្ឋានសំរាប់កំណត់អាករពិសេសលើទំនិញមួយចំនួន
- កាលបរិច្ឆេទនិងលេខបង្កាន់ដៃបង់ប្រាក់

បញ្ជីពិសេសត្រូវតែមាន ចុះលេខទំព័រ និង ចុះហត្ថលេខាបញ្ជាក់ជាមុនដោយនាយកទីចាត់ការគយឬអ្នកតំណាងដែលមានសិទ្ធិប្រទាន ។

២_ ចំពោះទំនិញផលិតឬធ្វើនៅព្រះរាជាណាចក្រកម្ពុជា :

- ស្តុកនៅថ្ងៃទី ៣១ ធ្នូ នៃឆ្នាំមុនៗ
- ការកត់ត្រាការធ្វើទំនិញពីមួយថ្ងៃទៅមួយថ្ងៃ
- ការបញ្ចេញទំនិញក៏ត្រូវធ្វើការកត់ត្រាពីមួយថ្ងៃទៅមួយថ្ងៃដែរ ។

បញ្ជីពិសេសត្រូវតែមានចុះលេខទំព័រនិងចុះហត្ថលេខាបញ្ជាក់ជាមុនដោយប្រធាននាយកដ្ឋានពន្ធដារ ឬអ្នកតំណាងដែលមានសិទ្ធិប្រទាន ។

## មាត្រា ២៥._

ចំពោះទំនិញផលិតឬធ្វើនៅព្រះរាជាណាចក្រកម្ពុជា អ្នកជាប់អាករពិសេសលើទំនិញមួយចំនួន ត្រូវជូនលិខិតប្រកាសពន្ធយ៉ាងយឺតបំផុតនៅថ្ងៃទី ១០ នៃខែនីមួយៗអោយទៅផ្នែកពន្ធដារ ដោយមានបញ្ជាក់អំពីមូលដ្ឋានកំណត់អាករ ដែលជាលទ្ធផលនៃប្រតិបត្តិការដែលបានសំរេចក្នុងខែមុន ។

លិខិតប្រកាសត្រូវមានកត់ត្រាបញ្ជាក់អំពីចំនួនប្រាក់អាករពិសេសលើទំនិញមួយចំនួន ដែលត្រូវបង់ និងត្រូវបង់ភ្ជាមនាឱកាសដាក់លិខិតប្រកាសពន្ធ ។

## មាត្រា ២៦._

អាករពិសេសលើទំនិញមួយចំនួន ចំពោះទំនិញនាំចូលត្រូវប្រមូលនាឱកាសនាំចូលដោយអង្គភាពគយ ក្នុងលក្ខខណ្ឌនិងតាមបទបញ្ញត្តិដូចគ្នានឹងពន្ធគយនិងអាករប្រើប្រាស់ ។

## មាត្រា ២៧._

បុគ្គលទាំងឡាយដែលលក់ផលិតផលស្ថិតក្នុងដែនអនុវត្តន៍នៃអាករពិសេសលើទំនិញមួយចំនួន ត្រូវបង្ហាញភស្តុតាងសំរាប់បញ្ជាក់ថា ផលិតផលដែលដាក់លក់ទាំងនេះ ពិតជាបានបង់អាករនេះរួចហើយនៅពេលបញ្ចូលក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ បើគ្មានភស្តុតាងបញ្ជាក់ទេ ផ្នែកពន្ធដារត្រូវគិតគូរនិងទារប្រាក់អាករដែលត្រូវបង់ និងត្រូវអនុវត្តទោសទណ្ឌជាធរមាន ។

## មាត្រា ២៨._

វិធានច្បាប់ទាំងឡាយស្តីពីអាករលើផលរបរ ដែលប្រមូលនៅផ្ទៃក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមិនផ្ទុយនឹងបទបញ្ញត្តិនៃជំពូកនេះ ត្រូវយកមកអនុវត្តចំពោះអាករពិសេសលើទំនិញផលិតឬធ្វើនៅកម្ពុជា ។

វិធានច្បាប់ទាំងនេះ គឺជាវិធានច្បាប់ចែងអំពីមូលដ្ឋានកំណត់ពន្ធ ការត្រួតពិនិត្យ ទោសបញ្ញត្តិ និងការប្រមូល ពន្ធ ។

## មាត្រា ២៩._

១_ និតិវិធីធម្មតានៃការកំណត់ពន្ធឡើងវិញ បន្ទាប់ពីការត្រួតពិនិត្យអាករពិសេសលើទំនិញមួយចំនួន ដែលប្រមូលដោយអង្គការពន្ធ គឺជានិតិវិធីដែលបានចែងនៅមាត្រា ២៩ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។

២_ និតិវិធីនៃការកំណត់ពន្ធជាឯកតោភាគីរបស់អង្គការពន្ធអាចអនុវត្តបាន ចំពោះករណីទាំងឡាយដូចមានចែងនៅមាត្រា ៥៨ នៃច្បាប់ដូចយោងខាងលើ ។ និតិវិធីដែលនេះអាចអនុវត្តបានក្នុងករណីដែលបញ្ជីពិសេសដូចមានចែងក្នុងចំណុច ២ នៃមាត្រា ២៩ នៃច្បាប់នេះមិនបានបង្ហាញអោយឃើញ ។

## មាត្រា ៣០._

បទបញ្ញត្តិនៃក្រឹត្យច្បាប់លេខ ២៤ ក្រ.ច ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៨៩ ស្តីពីពន្ធលើទំនិញក្នុងប្រទេសដែលផ្ទុយនឹងបទបញ្ញត្តិកំណត់ក្នុងផ្នែកនេះ ត្រូវលុបចោលចាប់ពីពេលដែលច្បាប់នេះចូលជាធរមាន ។ រាល់ការកែប្រែដែលបានកំណត់ក្នុងផ្នែកនេះ ពុំមានអនុភាពប្រតិសកម្មទេ ។

# ផ្នែកទី ៣

## បទបញ្ញត្តិស្តីពីការកែប្រែការបង់ប្រចាំខែនូវប្រាក់រំដោះពន្ធលើ ប្រាក់ចំណេញ ដែលត្រូវបង់ដោយសហគ្រាសជាប់ពន្ធតាមរបបពិត

**មាត្រា ៣១.–**

ចំពោះគ្រប់ប្រតិបត្តិការដែលសំរេចបានគិតចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ១៩៩៦ ចំនួនប្រាក់រំដោះត្រូវបង់ប្រចាំខែសំរាប់ពន្ធលើប្រាក់ចំណេញត្រូវកំណត់ ១% នៃផលរបរគិតរួមបញ្ចូលទាំងអាករគ្រប់ប្រភេទដែលសំរេចបានក្នុងខែមុន ។ ប្រាក់រំដោះនេះនឹងត្រូវបានផាត់ចេញពីចំនួនប្រាក់ពន្ធដែលត្រូវបង់នាពេលធ្វើការទូទាត់ប្រាក់ពន្ធជាស្ថាពរ ។

**មាត្រា ៣២.–**

ទោះបីលទ្ធផលសារពើពន្ធដែលបានធ្វើប្រកាសឬដែលបានទទួលស្គាល់យ៉ាងណាក្តី ប្រាក់ពន្ធលើប្រាក់ចំណេញ ដែលត្រូវបង់ដោយសហគ្រាសជាប់ពន្ធតាមរបបពិតមិនត្រូវតិចជាងប្រាក់ពន្ធអប្បបរមា ដែលមានចំនួនស្មើនឹង ១% នៃផលរបរប្រចាំឆ្នាំ ដោយគិតរួមបញ្ចូលទាំងអាករគ្រប់ប្រភេទផង និងមិនអាចផាត់ចេញពីប្រាក់រំដោះប្រចាំខែ សំរាប់ការិយបរិច្ឆេទបន្ទាប់ឬសងវិញឡើយ ។

បទបញ្ញត្តិស្តីពីពន្ធអប្បបរមា ដូចមានចែងនៅក្នុងមាត្រានេះ ត្រូវយកមកអនុវត្តជាលើកដំបូងសំរាប់ពេលពិនិត្យការិយបរិច្ឆេទដែលចាប់ផ្តើមពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៦

# ផ្នែកទី ៤

## បទបញ្ញត្តិស្តីពីការកំណត់អោយបានស្មើគ្នារវាង អត្រាអាករលើផលរបរ ជាមួយនឹងអត្រាអាករប្រើប្រាស់

**មាត្រា ៣៣.–**

ចាប់ពីថ្ងៃប្រកាសអោយប្រើច្បាប់នេះ គ្រប់ប្រតិបត្តិការដែលពីមុនជាប់អាករលើផលរបរ តាមអត្រា ២% ត្រូវជាប់អាករលើផលរបរតាមអត្រា ៤% ។ ប៉ុន្តែ ប្រតិបត្តិការទាំងឡាយនៃសកម្មភាពឧស្សាហកម្ម សិប្បកម្មនិងអណ្តូងរ៉ែ ត្រូវជាប់អាករលើផលរបរតាមអត្រា ១% ដដែល ។

# ជំពូកទី៥

## អវសានបញ្ញត្តិ

**មាត្រា ៣៤._**

បទបញ្ញត្តិនៃច្បាប់ទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៥._**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៩ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី ១ ។

ភ្នំពេញ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៩

ប្រធានរដ្ឋសភា

# ភាគទី ២

## បណ្ដាតារាងឧបសម្ព័ន្ធ
## នៃច្បាប់ស្ដីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុ
## សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥

# ការគ្រប់គ្រង ឆ្នាំ ១៩៩៥
## តារាង "ក" - ច្បាប់ហិរញ្ញវត្ថុកែតម្រូវ
## ចំណូលថវិកាចរន្តរបស់រដ្ឋ

ប្រមាណចំណូល តាមប្រភេទ ជំពូក ប្រការ កថាខណ្ឌ និង វាក្យខណ្ឌ

ឯកតា: លានរៀល

| ប្រការ | កថាខណ្ឌ | វាក្យខណ្ឌ | ការរាយមុខចំណូល | ការទាយតំលៃដំបូងច្បាប់ហិរញ្ញវត្ថុ ១៩៩៥ | ការទាយតំលៃកែប្រែច្បាប់ហិរញ្ញវត្ថុកែតម្រូវ | លំអៀងខាង ខ្វះ | លំអៀងខាង លើស |
|---|---|---|---|---|---|---|---|
| | | | សរុបរួមចំណូលថវិកាចរន្តរបស់រដ្ឋ | 1 058 600 | 1 283 000 | -87 134 | +251 643 |
| | | | សរុបចំណូលជាប្រចាំ | 581 100 | 694 000 | -53 156 | +169 756 |
| | | | ប្រភេទទី១: ពន្ធ និង អាករ | 461 500 | 466 350 | -44 792 | +49 642 |
| | | | ជំពូក១០: ពន្ធលើផលទុនប្រាក់ចំណេញ និង កំរៃទុន | 11 735 | 16 245 | | +4 510 |
| 01 | | | ពន្ធលើប្រាក់បៀវត្ស | 1 000 | 1 000 | | |
| 02 | | | ពន្ធលើប្រាក់ចំណេញរបស់រោងចក្រ និង ពាណិជ្ជកម្ម | 7 635 | 11 835 | | +4 200 |
| | 01 | | សហគ្រាសសាធារណៈ | 3 146 | 3 145 | -1 | |
| | | 01 | សហគ្រាសមជ្ឈិម | 2 846 | 2 845 | -1 | |
| | | 02 | សហគ្រាសខេត្តនានា | 300 | 300 | | |
| | 02 | | សហគ្រាសឯកជន | 4 489 | 8 690 | | +4 201 |
| 03 | | | ពន្ធលើប្រាក់ចំណេញនៃវិជ្ជាជីវៈ មិនមែនពាណិជ្ជកម្ម | | | | |
| 04 | | | ពន្ធលើផលទុននៃតម្លៃអចលនទ្រព្យ | | | | |
| 05 | | | ពន្ធលើផលទុននៃជួល_ផ្ទះសំបែង | 3 000 | 3 000 | | |
| 06 | | | ពន្ធលើតំលៃលើសអចលនទ្រព្យ | | | | |
| 07 | | | ពន្ធលើផលទុនកសិកម្ម | | | | |
| | 01 | | សកម្មភាពព្រៃឈើ | | | | |
| | 02 | | សកម្មភាពនេសាទ | | | | |
| | 03 | | អាជីវកម្មកសិកម្មផ្សេងៗទៀត | | | | |
| 08 | | | ពន្ធដីធ្លីលើដីទំនេរ | | | | |
| 20 | | | ពន្ធផ្សេងៗទៀតលើផលទុន_ប្រាក់ចំណេញ និង កំរៃទុន | 100 | 410 | | +310 |
| | | | ជំពូក១១: ពន្ធលើបេតិកភ័ណ្ឌ | 300 | 700 | | +400 |
| 01 | | | ពន្ធប្រថាប់ត្រា | 300 | 700 | | +400 |
| | 01 | | ពន្ធផ្ទេរមាតិការវាងអ្នកនៅរស់ | 300 | 700 | | +400 |
| | 02 | | ពន្ធផ្ទេរសិទ្ធិពីអ្នកស្លាប់ | | | | |

# ការគ្រប់គ្រង ឆ្នាំ ១៩៩៥
# តារាង "ក" - ច្បាប់ហិរញ្ញវត្ថុកែតំរូវ
## ចំណូលថវិកាចរន្តរបស់រដ្ឋ

សង្ខេបតារាងចំណូល តាមប្រភេទ ជំពូក ប្រការ កថាខណ្ឌ និង អនុកថាខណ្ឌ

ឯកតា៖លានរៀល

| ជំពូក | ប្រការ | កថាខណ្ឌ | អនុកថាខណ្ឌ | ការរាយមុខចំណូល | ការទាយតំលៃដំបូងច្បាប់ហិរញ្ញវត្ថុ ១៩៩៥ | ការទាយតំលៃកែប្រែច្បាប់ហិរញ្ញវត្ថុកែតំរូវ | លំអៀងខាង ខ្វះ | លំអៀងខាង លើស |
|---|---|---|---|---|---|---|---|---|
| 12 | | | | ជំពូក១២: ពន្ធផ្ទៃក្នុងលើទ្រព្យសម្បត្តិ និងសេវាកម្ម | 83 240 | 92 185 | -9 217 | +18 162 |
| | 01 | | | អាករលើផលរបរៈ របបផ្ទៃក្នុង | 7 347 | 13 550 | | +6 203 |
| | | 01 | | សហគ្រាសសាធារណៈ | 2 347 | 2 350 | | +3 |
| | | | 01 | សហគ្រាសមជ្ឈិម | 1 847 | 1 850 | | +3 |
| | | | 02 | សហគ្រាសខេត្តនានា | 500 | 500 | | |
| | | 02 | | សហគ្រាសឯកជន | 5 000 | 11 200 | | +6 200 |
| | 02 | | | អាករប្រើប្រាស់: របបនាំចូល | 65 437 | 59 000 | -6 437 | |
| | 03 | | | ពន្ធប៉ាតង់ | 812 | 1 200 | | +388 |
| | 04 | | | អាករពិសេសលើទំនិញមួយចំនួន | 4 244 | 15 815 | | +11 571 |
| | 05 | | | ពន្ធសត្តឃាត | 200 | 200 | | |
| | 06 | | | ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ | 2 200 | 2 200 | | |
| | 07 | | | អាករស្នាក់នៅ | 3 000 | 220 | -2 780 | |
| 13 | | | | ជំពូក១៣: ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 364 325 | 347 640 | -35 375 | +18 690 |
| | 01 | | | ពន្ធ និង អាករលើការនាំចូល | 355 125 | 322 500 | -35 375 | +2 750 |
| | | 01 | | ពន្ធលើការនាំចូល | 266 975 | 231 600 | -35 375 | |
| | | 02 | | កំរៃយកមុនលើផលិតផលប្រេងកាត | 1 300 | 1 300 | | |
| | | 03 | | កំរៃយកមុនលើការបារឥយក្នុងការនាំចូល | 100 | 100 | | |
| | | 04 | | ពន្ធលើផលិតផលប្រេងកាត | 86 650 | 89 400 | | +2 750 |
| | | 10 | | ពន្ធ និង អាករផ្សេងៗទៀតពីការនាំចូល | 100 | 100 | | |
| | 02 | | | អាករពីការនាំចេញ | 5 200 | 18 840 | | +13 640 |
| | | 01 | | អាករលើការនាំចេញ | 5 000 | 18 640 | | +13 640 |
| | | 02 | | កំរៃយកពីមុនលើការបារឥយក្នុងការនាំចេញ | 100 | 100 | | |
| | | 10 | | ពន្ធ និង អាករផ្សេងៗទៀតពីការនាំចេញ | 100 | 100 | | |
| | 03 | | | ការផាកពិន័យរបស់គយ | 4 000 | 6 300 | | +2 300 |

# ការគ្រប់គ្រង ឆ្នាំ ១៩៩៥
## តារាង "ក" - ច្បាប់ហិរញ្ញវត្ថុកែតំរូវ
## *ចំណូលថវិកាចរន្តរបស់រដ្ឋ*

ការប្រមាណចំណូល តាមប្រភេទ ជំពូក ប្រការ កថាខណ្ឌ និង អនុកថាខណ្ឌ — ឯកតា:លានរៀល

| ជំពូក | ប្រការ | កថាខណ្ឌ | អនុកថាខណ្ឌ | ការអោយមុខចំណូល | ការទាយតំលៃដំបូងច្បាប់ហិរញ្ញវត្ថុ ១៩៩៥ | ការទាយតំលៃកែប្រែច្បាប់ហិរញ្ញវត្ថុកែតំរូវ | លំអៀងខាង ខ្វះ | លើស |
|---|---|---|---|---|---|---|---|---|
| 14 | | | | ជំពូក៧៤: ចំណូលសារពើពន្ធផ្សេងៗទៀត | 1 900 | 9 580 | -200 | +7 880 |
| | 01 | | | ពន្ធតែមប្រិ | 200 | 200 | | |
| | 02 | | | ពន្ធលើសារលិខិតស៊ីវិល និង តុលាការ | | | | |
| | 03 | | | អាករលើការសាងសង់ | | | | |
| | 04 | | | ការផាកពិន័យ និង ទោសប្បញ្ញត្តិសារពើពន្ធ | 100 | 500 | | +400 |
| | 05 | | | អាករលើយានយន្តនាំចូលដោយផ្ទុយនឹងច្បាប់ | | 7 400 | | +7 400 |
| | 06 | | | អាករព្រលានយន្តហោះ | 1 500 | 1 300 | -200 | |
| | 10 | | | ចំណូលសារពើពន្ធផ្សេងៗទៀតតាមមុខពន្ធនានា | 100 | 180 | | +80 |
| | | | | ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ | 119 600 | 227 650 | -8 364 | +120 114 |
| 20 | | | | ជំពូក៧០: ផលទុននៃទ្រព្យសម្បត្តិ | 48 362 | 159 950 | -4 826 | +120 114 |
| | 01 | | | ផលនេសាទ | 6 100 | 6 100 | | |
| | 02 | | | ផលព្រៃឈើ | 3 825 | 85 900 | | +82 075 |
| | 03 | | | ផលទុនបានមកពីសហគ្រាសសាធារណៈ | 34 602 | 32 410 | -4 722 | +2 530 |
| | | 01 | | ការចូលរួមចំណេញសហគ្រាស | 12 783 | 11 400 | -1 383 | |
| | | | 01 | សហគ្រាសមជ្ឈិម | 11 783 | 10 400 | -1 383 | |
| | | | 02 | សហគ្រាសខេត្តនានា | 1 000 | 1 000 | | |
| | | 02 | | ការបង់ប្រាក់រំលស់ឡើងវិញ | 2 808 | 900 | -1 908 | |
| | | | 01 | សហគ្រាសមជ្ឈិម | 2 808 | 900 | -1 908 | |
| | | | 02 | សហគ្រាសខេត្តនានា | | | | |
| | | 03 | | ចំនួនលើសនៃទុនចល័ត | 475 | 475 | | |
| | | 04 | | សេវាកម្មនៃការគ្រប់គ្រងការរបស់សហគ្រាសសាធារណៈ | | | | |
| | | 05 | | ប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ | 491 | 500 | | +9 |
| | | 06 | | ផលទុនរបស់អាកាសចរណ៍ស៊ីវិល | 14 040 | 14 040 | | |
| | | 07 | | ផលទុននៃសកម្មភាពភាពយន្ត | 4 | 5 | | +1 |
| | | 08 | | ផលទុននៃសកម្មភាពទេសចរណ៍ | 2 031 | 600 | -1 431 | |

ព្រះរាជាណាចក្រកម្ពុជា

# ការគ្រប់គ្រង ឆ្នាំ ១៩៩៥
## តារាង "ក" - ច្បាប់ហិរញ្ញវត្ថុកែតំរូវ
## ចំណូលថវិកាចរន្តរបស់រដ្ឋ

សេចក្តីលំអិតចំណូល តាមប្រភេទ ជំពូក ប្រការ កថាខណ្ឌ និង អនុកថាខណ្ឌ

ឯកតា: លានរៀល

| ជំពូក | ប្រការ | កថាខណ្ឌ | អនុកថាខណ្ឌ | ការវាយមុខចំណូល | ការទាយតំលៃដំបូងច្បាប់ហិរញ្ញវត្ថុ ១៩៩៥ | ការទាយតំលៃកែប្រែច្បាប់ហិរញ្ញវត្ថុកែតំរូវ | លំអៀងគ្នា ខ្វះ | លើស |
|---|---|---|---|---|---|---|---|---|
| | | 09 | | ការលក់សំភារៈបរិក្ខារ | 437 | 550 | | +113 |
| | | 10 | | ការជួលសំភារៈបរិក្ខារ | | | | |
| | | 11 | | ផលនៃការដឹកជញ្ជូនទំនិញ | 95 | 110 | | +15 |
| | | 12 | | ផលនៃប្រតិបត្តិការពាណិជ្ជកម្ម | 881 | 1 700 | | +819 |
| | | 20 | | ផលចូលផ្សេងៗទៀតរបស់សហគ្រាសសាធារណៈ | 557 | 2 130 | | +1 573 |
| | 04 | | | កំរៃយកមកពីសម្បទានទ្រព្យសម្បត្តិរដ្ឋ | 2 454 | 26 500 | | +24 046 |
| | | 01 | | សម្បទានដីប្រេងកាត | 1 514 | 1 515 | | +1 |
| | | 02 | | សម្បទានដីរ៉ែ | 940 | 985 | | +45 |
| | | 10 | | សម្បទានផ្សេងៗទៀត | | 24 000 | | +24 000 |
| | 05 | | | ពន្ធលើការកាន់កាប់កម្មសិទ្ធិសាធារណៈ | | 3 700 | | +3 700 |
| | | 01 | | ផលនៃការជួលកន្លែងលក់ដូរក្នុងផ្សារ | | 2 100 | | +2 100 |
| | | 02 | | ពន្ធចំណតយានយន្ត | | 400 | | +400 |
| | | 03 | | ពន្ធកំពង់ចម្លង | | 1 000 | | +1 000 |
| | | 04 | | ពន្ធកន្លែងលក់ដោយការដេញថ្លៃ | | 200 | | +200 |
| | 06 | | | ការជួលអចលនវត្ថុ | 737 | 3 500 | | +2 763 |
| | 07 | | | ផលពីការលក់ផ្លែឈើ | 500 | 1 800 | | +1 300 |
| | 08 | | | ផលបានមកពីការលក់ទ្រព្យសម្បត្តិកំទេចកំទី សត្វពាហនៈយានយន្តចាស់ហួសកាលគ្មានម្ចាស់ និង ទំនិញបោះបង់ចោល | | | | |
| | 09 | | | ផលពីការលក់ចលនវត្ថុចាស់របស់រដ្ឋ | 17 | 15 | -2 | |
| | 20 | | | ផលផ្សេងៗទៀតពីទ្រព្យសម្បត្តិរដ្ឋ | 127 | 25 | -102 | |
| 21 | | | | ជំពូក២១: ចំណូលផ្សេងៗទៀតពុំមែនសារពើពន្ធ | 71 238 | 67 700 | -3 538 | |
| | 01 | | | ផលចូលប្រៃសណីយ៍ និង ទូរគមនាគមន៍ | 61 686 | 61 685 | -1 | |
| | 02 | | | ផលចូល វិទ្យុ ទូរទស្សន៍ ការផ្សាយ | 131 | 130 | -1 | |
| | 03 | | | ចំណូលនៃសេវាកម្មសាធារណៈ | 5 076 | 3 555 | -1 521 | |
| | | 01 | | កំរៃនៃការថែទាំ | 48 | 50 | | +2 |
| | | 02 | | ការលក់សំភារៈសិក្សា | 2 | | -2 | |
| | | 03 | | រោងរនៃស្ពានខ្ពស់ | 2 432 | 400 | -2 032 | |

# ការគ្រប់គ្រង ឆ្នាំ ១៩៩៥
## តារាង "ក" - ច្បាប់ហិរញ្ញវត្ថុកែតំរូវ
## ចំណូលថវិកាទូទៅរបស់រដ្ឋ

ការបែងចែកចំណូល តាមប្រភេទ ជំពូក ប្រការ កថាខណ្ឌ និង អនុកថាខណ្ឌ

ឯកតា: លានរៀល

| ជំពូក | ប្រការ | កថាខណ្ឌ | អនុកថាខណ្ឌ | ការរាយមុខចំណូល | ការបោះតំលៃដំបូងច្បាប់ហិរញ្ញវត្ថុ ១៩៩៥ | ការបោះតំលៃកែប្រែច្បាប់ហិរញ្ញវត្ថុកែតំរូវ | លំអៀងខាង ខ្វះ | លើស |
|---|---|---|---|---|---|---|---|---|
| | | 04 | | ផលខូចនៃសកម្មភាពព្រៃឈើ | 56 | 700 | | +644 |
| | | 05 | | ពន្ធលើអាជ្ញាប័ណ្ណនាំឈើចេញ | 100 | 800 | | +700 |
| | | 06 | | ការត្រួតពិនិត្យគុណភាពផលិតផល | 282 | 280 | -2 | |
| | | 07 | | ពន្ធលើការបង្កើតសហគ្រាស | | 65 | | +65 |
| | | 08 | | ការបង់ប្រាក់ធានាសំរាប់បង្កើតសហគ្រាស | | 40 | | +40 |
| | | 09 | | ការលក់ឯកសារគយ | 100 | 100 | | |
| | | 10 | | លតាប័ត្រ និង លិខិតបោះពុម្ពផ្សេងៗរបស់គយ | 1 300 | 800 | -500 | |
| | | 11 | | ឯកសារផ្សេងៗទៀត | 78 | 80 | | +2 |
| | | 12 | | ការលក់ឯកសារ និង លិខិតបោះពុម្ពរបស់ពន្ធដារ | | 10 | | +10 |
| | | 13 | | ផលនៃការលក់ផ្លាកលេខ | | 150 | | +150 |
| | | 30 | | ចំណូលផ្សេងៗទៀតរបស់សេវាកម្មសាធារណៈ | 678 | 80 | -598 | |
| | 04 | | | ប្រាក់ចំណេញធនាគារនិងការប្រាក់ផ្សេងៗ | 231 | 230 | -1 | |
| | 05 | | | ចំណូលក្រៅសារពើពន្ធរបស់ខេត្តក្រុង | 2 218 | 800 | -1 418 | |
| | 20 | | | ចំណូលផ្សេងៗក្រៅពីសារពើពន្ធ | 1 896 | 1 300 | -596 | |
| | | | | **សរុបចំណូលជាមូលធន** | 477 500 | 589 000 | -33 978 | +81 887 |
| | | | | **ប្រភេទទី២: ចំណូលជាមូលធន** | 477 500 | 589 000 | -33 978 | +81 887 |
| 30 | | | | ជំពូក៣០: ចំណូលផ្ទាល់ជាមូលធន | | 380 | | +380 |
| | 01 | | | ការលក់ទ្រព្យសម្បត្តិនៃមូលធនថេរ | | 380 | | +380 |
| | 02 | | | ការលក់ដីធ្លី | | | | |
| | 03 | | | ការលក់ទ្រព្យសកម្មអរូបីយ និង ហិរញ្ញវត្ថុ | | | | |
| | 15 | | | ចំណូលផ្ទាល់ផ្សេងៗទៀតជាមូលធន | | | | |

# ការគ្រប់គ្រង ឆ្នាំ ១៩៩៥
## តារាង "ក" - ច្បាប់ហិរញ្ញវត្ថុកែតម្រូវ
## ចំណូលថវិកាទូទៅរបស់រដ្ឋ

ការប្រមាណចំណូល តាមប្រភេទ ជំពូក ប្រការ កថាខណ្ឌ និង អនុកថាខណ្ឌ

ឯកតា: លានរៀល

| ជំពូក | ប្រការ | កថាខណ្ឌ | អនុកថាខណ្ឌ | ការរាយមុខចំណូល | ការបោះតំលៃ ដំបូងច្បាប់ហិរញ្ញវត្ថុ ១៩៩៥ | ការបោះតំលៃកែប្រែ ច្បាប់ហិរញ្ញវត្ថុ កែតម្រូវ | លំអៀងខាង ខ្វះ | លំអៀងខាង លើស |
|---|---|---|---|---|---|---|---|---|
| 31 | | | | ជំពូក៣១: អំណោយពិសេស | 291 380 | 397 087 | | +81 507 |
| | 01 | | | ជំនួយមនុស្សធម៌ | | | | |
| | | 01 | | .................................... | | | | |
| | 02 | | | មូលនិធិបដិភាគ | 14 510 | 69 240 | | +54 730 |
| | | 01 | | ជប៉ុន | 14 510 | 47 600 | | +33 090 |
| | | 02 | | អាល្លឺម៉ង់ | | | | |
| | | 03 | | បែលហ្ស៊ិក | | | | |
| | | 04 | | ចក្រភពអង់គ្លេស | | 9 640 | | +9 640 |
| | | 05 | | បារាំង | | | | |
| | | 06 | | អង្គការសហប្រជាជាតិ | | | | |
| | | 07 | | អ៊ីតាលី | | | | |
| | | 08 | | ស៊ុយអែត | | 12 000 | | +12 000 |
| | | 30 | | ផ្សេងៗទៀត | | | | |
| | 03 | | | អំណោយផ្សេងៗទៀតពិសេស | 276 870 | 303 647 | | +26 777 |
| | | 01 | | ជប៉ុន | | | | |
| | | 02 | | សហរដ្ឋអាមេរិក | | | | |
| | | 03 | | អង្គការសហប្រជាជាតិ | | | | |
| | | 04 | | បារាំង | | | | |
| | | 05 | | អូស្ត្រាលី | | | | |
| | | 06 | | ស៊ុយអែត | | | | |
| | | 07 | | ចក្រភពអង់គ្លេស | | | | |
| | | 08 | | អាល្លឺម៉ង់ | | | | |
| | | 30 | | ផ្សេងៗទៀត | | | | |
| | 04 | | | អំណោយដោយឡែកសំរាប់រំលស់បំណុល | | 24 200 | | +24 200 |

ព្រះរាជាណាចក្រកម្ពុជា

# ការគ្រប់គ្រង ឆ្នាំ ១៩៩៥
## តារាង "ក" - ច្បាប់ហិរញ្ញវត្ថុកែតម្រូវ
## ចំណូលថវិកាចរន្តរបស់រដ្ឋ

ការប្រមាណចំណូល តាមប្រភេទ ជំពូក ប្រការ កថាខណ្ឌ និង វាក្យខណ្ឌ

ឯកតា: លានរៀល

| ជំពូក | ប្រការ | កថាខណ្ឌ | វាក្យខណ្ឌ | ការរាយមុខចំណូល | ការទាយតម្លៃ ដំបូងច្បាប់ហិរញ្ញវត្ថុ ១៩៩៥ | ការទាយតម្លៃកែប្រែ ច្បាប់ហិរញ្ញវត្ថុ កែតម្រូវ | លំអៀងខាង ខ្វះ | លើស |
|---|---|---|---|---|---|---|---|---|
| 32 | | | | ជំពូក៣២: ប្រភពទ្រព្យសម្បត្តិបានមកពីការខ្ចីបុល | 186 120 | 191 533 | -33 978 | |
| | 01 | | | ប្រភពទុនខ្ចីផ្ទៃក្នុង | 12 000 | 12 000 | | |
| | | 01 | | ប្រភពទុនខ្ចីផ្ទៃក្នុងបានមកពីប្រព័ន្ធធនាគារ | 12 000 | 12 000 | | |
| | | | | ............................... | | | | |
| | | 02 | | ប្រភពទុនខ្ចីផ្ទៃក្នុងផ្សេងៗទៀត | | | | |
| | | | | ............................... | | | | |
| | 02 | | | ប្រភពទុនខ្ចីពីបរទេស | 174 120 | 140 142 | -33 978 | |
| | | 01 | | ប្រភពទុនខ្ចីពីបរទេសបានមកពីអង្គការអន្តរជាតិនានា | 174 120 | 140 142 | -33 978 | |
| | | | 01 | ធនាគារពិភពលោក | 130 590 | 92 446 | -38 144 | |
| | | | | មូលនិធិបរិភោគ | 101 570 | 71 689 | -29 881 | |
| | | | | គំរោងខ្ចី | 29 020 | 20 757 | -8 263 | |
| | | | 02 | ធនាគារអាស៊ីសំរាប់អភិវឌ្ឍន៍ | 43 530 | 47 696 | | +4 166 |
| | | | | មូលនិធិបរិភោគ | | | | |
| | | | | គំរោងខ្ចី | 43 530 | 47 696 | | +4 166 |
| | | | | ............................... | | | | |
| | | 02 | | ប្រភពទុនខ្ចីពីបរទេសបានមកពីរដ្ឋាភិបាល និង អង្គការទំនាក់ទំនង | | | | |
| | | | | ............................... | | | | |
| | | 03 | | ប្រភពទុនខ្ចីពីបរទេសបានមកពីអង្គការឯកជននានា | | 39 391 | | +39 391 |
| | | | | ............................... | | | | |

# ការគ្រប់គ្រង ឆ្នាំ ១៩៩៥

## តារាង "ឃ" ‑ ច្បាប់ហិរញ្ញវត្ថុកែតម្រូវ

## *ចំណាយជាមូលធននៃថវិកាទូទៅរបស់រដ្ឋ*

តារាងសរុបតាមក្រសួង តាមប្រភេទវិនិយោគ និង តាមប្រភពហិរញ្ញប្បទាន

លានរៀល

| ក្រសួងនានា | សរុប ចំណាយ ជាមូលធន | ជំពូក ៥០ និង ៥១ ‑ ឥណទានវិនិយោគ | | | | ជំពូក ៥២ ប្រតិបត្តិការហិរញ្ញវត្ថុ | ជំពូក ៥៣ ការទូទាត់ប្រាក់ខ្ចី បុល |
|---|---|---|---|---|---|---|---|
| | | សរុប ទុនវិនិយោគ | ជំពូក ៥០ វិនិយោគក្នុងស្រុក | | ជំពូក ៥១ វិនិយោគពីបរទេស | | |
| | | | *សាងសង់_ទិញសំភារៈ* | *ឥណទានក្នុងស្រុក* | *សាងសង់_ទិញសំភារៈ* | | |
| សរុបរួមចំណាយជាមូលធន | 490 800 | 438 500 | 51 900 | 14 500 | 372 100 | | 52 300 |
| ១_ព្រះបរមរាជវាំង | 1 800 | 1 800 | 1 800 | | | | |
| ២_សភាជាតិ | 370 | 370 | 370 | | | | |
| ៣_ទីស្តីការគណៈរដ្ឋមន្ត្រី | 2 665 | 2 665 | 2 665 | | | | |
| *១_គណៈរដ្ឋមន្ត្រី* | 2 295 | 2 295 | 2 295 | | | | |
| *៤_ទំនាក់ទំនងជាមួយសភា* | 30 | 30 | 30 | | | | |
| *៦_មុខងារសាធារណៈ* | 40 | 40 | 40 | | | | |
| *៧_អាកាសចរណ៍ស៊ីវិល* | 300 | 300 | 300 | | | | |
| ៤_ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | 200 | 200 | 200 | | | | |
| ៥_ក្រសួងការពារជាតិ | | | | | | | |
| ៦_ក្រសួងមហាផ្ទៃ | 21 540 | 21 540 | 1 440 | 900 | 19 200 | | |
| *១_សន្តិសុខសាធារណៈ* | | | | | | | |
| *២_រដ្ឋបាលទូទៅ* | 21 540 | 21 540 | 1 440 | 900 | 19 200 | | |
| *៩_ខេត្តនានា* | | | | | | | |
| ៧_ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | 100 060 | 47 760 | 3 180 | 4 580 | 40 000 | | 52 300 |
| *១_ក្រសួង* | 99 575 | 47 275 | 2 695 | 4 580 | 40 000 | | 52 300 |
| *៩_ខេត្តនានា* | 485 | 485 | 485 | | | | |
| ៨_ក្រសួងពត៌មាន | 2 840 | 2 840 | 2 840 | | | | |
| *១_ក្រសួង* | 2 600 | 2 600 | 2 600 | | | | |
| *៩_ខេត្តនានា* | 240 | 240 | 240 | | | | |
| ៩_ក្រសួងសាធារណៈការនិង ដឹកជញ្ជូន | 122 430 | 122 430 | 22 510 | 2 420 | 97 500 | | |
| *១_ក្រសួង* | 119 155 | 119 155 | 19 235 | 2 420 | 97 500 | | |
| *៩_ខេត្តនានា* | 3 275 | 3 275 | 3 275 | | | | |
| ១០_ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | 57 955 | 57 955 | 7 705 | 1 750 | 48 500 | | |
| *១_ក្រសួង* | 57 955 | 57 955 | 7 705 | 1 750 | 48 500 | | |
| *៩_ខេត្តនានា* | | | | | | | |

ព្រះរាជាណាចក្រកម្ពុជា

# ការគ្រប់គ្រង ឆ្នាំ ១៩៩៥

## តារាង "ឃ" - ច្បាប់ហិរញ្ញវត្ថុកែតម្រូវ

## *ចំណាយជាមូលធននៃថវិកាទូទៅរបស់រដ្ឋ*

ការប្រមូលសរុបតាមក្រសួង តាមប្រភេទវិនិយោគ និង តាមប្រភពហិរញ្ញប្បទាន

លានរៀល

| ក្រសួងនានា | សរុប ចំណាយ ជាមូលធន | ជំពូក ៥០ និង ៥១ - ឥណទានវិនិយោគ: សរុប ទុនវិនិយោគ | ជំពូក ៥០ វិនិយោគក្នុងស្រុក: *សាងសង់-គ្រឿងសំភារៈ* | ជំពូក ៥០ វិនិយោគក្នុងស្រុក: *ថវិកាក្នុងស្រុក* | ជំពូក ៥១ វិនិយោគពីបរទេស: *សាងសង់-គ្រឿងសំភារៈ* | ជំពូក ៥២ ប្រតិបត្តិការ ហិរញ្ញវត្ថុ | ជំពូក ៥៣ ការទូទាត់ប្រាក់ដើម បំណុល |
|---|---|---|---|---|---|---|---|
| ១១-ក្រសួងយុត្តិធម៌ | 370 | 370 | 370 | | | | |
| *១-ក្រសួង* | 310 | 310 | 310 | | | | |
| *២-តុលាការជាន់ខ្ពស់បំផុត* | 30 | 30 | 30 | | | | |
| *៣-សាលាឧទ្ធរណ៍* | 30 | 30 | 30 | | | | |
| *៤-ខេត្តនានា* | | | | | | | |
| ១២-ក្រសួងអប់រំយុវជននិងកីឡា | 45 360 | 45 360 | 1 820 | 1 440 | 42 100 | | |
| *១-អប់រំ* | 43 940 | 43 940 | 400 | 1 440 | 42 100 | | |
| *២-ឧត្តមសិក្សា* | 1 200 | 1 200 | 1 200 | | | | |
| *៣-យុវជននិងកីឡា* | 220 | 220 | 220 | | | | |
| *៤-ខេត្តនានា* | | | | | | | |
| ១៣-ក្រសួងពាណិជ្ជកម្ម | 550 | 550 | 550 | | | | |
| *១-ក្រសួង* | 550 | 550 | 550 | | | | |
| *៤-ខេត្តនានា* | | | | | | | |
| ១៤-ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល | 57 500 | 57 500 | 200 | 3 100 | 54 200 | | |
| *១-ក្រសួង* | 57 500 | 57 500 | 200 | 3 100 | 54 200 | | |
| *៤-ខេត្តនានា* | | | | | | | |
| ១៥-ក្រសួងផែនការ | 110 | 110 | 80 | 30 | | | |
| *១-ក្រសួង* | 110 | 110 | 80 | 30 | | | |
| *៤-ខេត្តនានា* | | | | | | | |
| ១៦-ក្រសួងសុខាភិបាល | 25 550 | 25 550 | 3 900 | 250 | 21 400 | | |
| *១-ក្រសួង* | 25 550 | 25 550 | 3 900 | 250 | 21 400 | | |
| *៤-ខេត្តនានា* | | | | | | | |
| ១៧-ក្រសួងទេសចរណ៍ | 375 | 375 | 375 | | | | |
| *១-ក្រសួង* | 375 | 375 | 375 | | | | |
| *៤-ខេត្តនានា* | | | | | | | |
| ១៨-ក្រសួងធម្មការនិង កិច្ចការសាសនា | 30 | 30 | 30 | | | | |
| *១-ក្រសួង* | 30 | 30 | 30 | | | | |
| *៤-ខេត្តនានា* | | | | | | | |
| ១៩-ក្រសួងប្រៃសណីយ៍និង ទូរគមនាគមន៍ | 550 | 550 | 550 | | | | |
| *១-ក្រសួង* | 550 | 550 | 550 | | | | |
| *៤-ខេត្តនានា* | | | | | | | |

# ការគ្រប់គ្រង ឆ្នាំ ១៩៩៥

## តារាង "ឃ" ~ ច្បាប់ហិរញ្ញវត្ថុកែតំរូវ

## *ចំណាយជាមូលធនលើថវិកាទូទៅរបស់រដ្ឋ*

ការបូកសរុបតាមក្រសួង តាមប្រភេទវិនិយោគ និង តាមប្រភពហិរញ្ញប្បទាន

លានរៀល

| ក្រសួងនានា | សរុប ចំណាយ ជាមូលធន | ជំពូក ៥០ និង ៥១ _ ឥណទានវិនិយោគ | | | | | ជំពូក ៥២ ប្រតិបត្តិការហិរញ្ញវត្ថុ | ជំពូក ៥៣ ការទូទាត់ប្រាក់ខ្ចីបុល |
|---|---|---|---|---|---|---|---|---|
| | | សរុប ឥណទានវិនិយោគ | ជំពូក ៥០ វិនិយោគក្នុងស្រុក | | ជំពូក ៥១ វិនិយោគពីបរទេស | | | |
| | | | *សាងសង់_ទិញសំភារៈ* | *ថវិកាក្នុងស្រុក* | *សាងសង់_ទិញសំភារៈ* | | | |
| ២០_ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | 295 | 295 | 295 | | | | | |
| *១_ក្រសួង* | 295 | 295 | 295 | | | | | |
| *៤_ខេត្តនានា* | | | | | | | | |
| ២១_ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន | 350 | 350 | 350 | | | | | |
| *១_ក្រសួង* | 350 | 350 | 350 | | | | | |
| *៤_ខេត្តនានា* | | | | | | | | |
| ២២_ក្រសួងបរិស្ថាន | 470 | 470 | 470 | | | | | |
| *១_ក្រសួង* | 470 | 470 | 470 | | | | | |
| *៤_ខេត្តនានា* | | | | | | | | |
| ២៣_ក្រសួងអភិវឌ្ឍន៍ជនបទ | 49 260 | 49 260 | 30 | 30 | 49 200 | | | |
| *១_ក្រសួង* | 49 260 | 49 260 | 30 | 30 | 49 200 | | | |
| *៤_ខេត្តនានា* | | | | | | | | |
| ២៤_ក្រសួងកិច្ចការនារី | 170 | 170 | 170 | | | | | |
| *១_ក្រសួង* | 170 | 170 | 170 | | | | | |
| *៤_ខេត្តនានា* | | | | | | | | |
| ៩៩_ចំណាយផ្សេងៗនិង ពុំបានគ្រោងទុក | | | | | | | | |

(១) ក្នុងនោះ ៤ ៩០០ លានរៀល ចាយជូនជាបណ្ដោះអាសន្នត្រូវបែងចែកក្នុងជំពូក៥០

ព្រះរាជាណាចក្រកម្ពុជា

# ការគ្រប់គ្រង ឆ្នាំ ១៩៩៥

## តារាង "ខ" - ច្បាប់ហិរញ្ញវត្ថុកែតំរូវ

## ចំណាយថវិកាទូទៅរបស់រដ្ឋ

ការបូកសរុបចំណាយតាមក្រសួងនិងតាមប្រភេទ

ឯកតាគិតជាលានរៀល

| ប្រភេទ / ក្រសួងនានា / ផ្នែក | សរុបចំណាយ | សរុបចំណាយជាប្រចាំ | 1<br>ប្រភេទទី១: មធ្យោបាយសេវា | 2<br>ប្រភេទទី២: ការប្រាក់នៃការខ្ចីបុល | 3<br>ប្រភេទទី៣: អន្តរាគមន៍សាធារណៈ | 4<br>ប្រភេទទី៤: ចំណាយផ្សេងៗ និង ចំណាយមិនបានគ្រោងទុក | 5<br>ប្រភេទទី៥: ចំណាយជាមូលធន |
|---|---|---|---|---|---|---|---|
| **សរុបរួមចំណាយ** | 1 283 000 | 792 200 | 688 110 | 19 700 | 80 590 | 3 800 | 490 800 |
| ១_ព្រះបរមរាជវាំង | 13 600 | 11 800 | 8 290 | | 3 510 | | 1 800 |
| ២_សភាជាតិ | 9 800 | 9 430 | 9 190 | | 240 | | 370 |
| ៣_ទីស្តីការគណៈរដ្ឋមន្ត្រី | 30 010 | 27 345 | 21 815 | | 5 530 | | 2 665 |
| ១_គណៈរដ្ឋមន្ត្រី | 25 850 | 23 555 | 18 190 | | 5 365 | | 2 295 |
| ៤_ទំនាក់ទំនងជាមួយសភា | 640 | 610 | 600 | | 10 | | 30 |
| ៦_មុខងារសាធារណៈ | 380 | 340 | 335 | | 5 | | 40 |
| ៧_អាកាសចរណ៍ស៊ីវិល | 3 140 | 2 840 | 2 690 | | 150 | | 300 |
| ៤_ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | 23 150 | 22 950 | 21 705 | | 1 245 | | 200 |
| ៥_ក្រសួងការពារជាតិ | 308 500 | 308 500 | 301 900 | | 6 600 | | |
| ៦_ក្រសួងមហាផ្ទៃ | 154 235 | 132 695 | 130 235 | | 2 460 | | 21 540 |
| ១_សន្តិសុខសាធារណៈ | 104 370 | 104 370 | 103 315 | | 1 055 | | |
| ២_រដ្ឋបាលទូទៅ | 27 570 | 6 030 | 4 865 | | 1 165 | | 21 540 |
| ៩_ខេត្តនានា | 22 295 | 22 295 | 22 055 | | 240 | | |
| ៧_ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | 136 015 | 35 955 | 9 980 | 19 700 | 6 275 | | 100 060 |
| ១_ក្រសួង | 134 095 | 34 520 | 8 670 | 19 700 | (១) 6 150 | | (៦) 99 575 |
| ៩_ខេត្តនានា | 1 920 | 1 435 | 1 310 | | 125 | | 485 |
| ៨_ក្រសួងព័ត៌មាន | 7 785 | 4 945 | 4 830 | | 115 | | 2 840 |
| ១_ក្រសួង | 6 150 | 3 550 | 3 490 | | 60 | | 2 600 |
| ៩_ខេត្តនានា | 1 635 | 1 395 | 1 340 | | 55 | | 240 |
| ៩_ក្រសួងសាធារណៈការនិងដឹកជញ្ជូន | 133 770 | 11 340 | 6 020 | | 5 320 | | 122 430 |
| ១_ក្រសួង | 126 285 | 7 130 | 1 920 | | 5 210 | | 119 155 |
| ៩_ខេត្តនានា | 7 485 | 4 210 | 4 100 | | 110 | | 3 275 |
| ១០_ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | 72 150 | 14 195 | 11 890 | | 2 305 | | 57 955 |
| ១_ក្រសួង | 65 760 | 7 805 | 6 660 | | 1 145 | | 57 955 |
| ៩_ខេត្តនានា | 6 390 | 6 390 | 5 230 | | 1 160 | | |

# ការគ្រប់គ្រង ឆ្នាំ ១៩៩៥

## តារាង "ខ" - ច្បាប់ហិរញ្ញវត្ថុកែតំរូវ

## ចំណាយថវិកាទូទៅរបស់រដ្ឋ

តារាងសរុបចំណាយតាមក្រសួងនិងតាមប្រភេទ

ឯកតាគិតជាលានរៀល

| ប្រភេទ / ក្រសួងនានា / ផ្នែក | សរុបចំណាយ | សរុបចំណាយជាប្រចាំ | 1 ប្រភេទទី១: មធ្យោបាយសេវា | 2 ប្រភេទទី២: ការប្រាក់នៃការខ្ចីបុល | 3 ប្រភេទទី៣: អន្តរាគមន៍សាធារណៈ | 4 ប្រភេទទី៤: ចំណាយផ្សេងៗ និង ចំណាយមិនបានព្យាករទុក | 5 ប្រភេទទី៥: ចំណាយជាមូលធន |
|---|---|---|---|---|---|---|---|
| ១១_ក្រសួងយុត្តិធម៌ | 3 435 | 3 065 | 2 975 | | 90 | | 370 |
| ១_ក្រសួង | 1 800 | 1 490 | 1 465 | | 25 | | 310 |
| ២_តុលាការជាន់ខ្ពស់បំផុត | 470 | 440 | 425 | | 15 | | 30 |
| ៣_សាលាឧទ្ធរណ៍ | 190 | 160 | 155 | | 5 | | 30 |
| ៤_ខេត្តនានា | 975 | 975 | 930 | | 45 | | |
| ១២_ក្រសួងអប់រំយុវជននិងកីឡា | 124 420 | 79 060 | 77 155 | | 1 905 | | 45 360 |
| ១_អប់រំ | 55 065 | 11 125 | 10 945 | | 180 | | 43 940 |
| ២_ឧត្តមសិក្សា | 3 420 | 2 220 | 1 895 | | 325 | | 1 200 |
| ៣_យុវជននិងកីឡា | 1 765 | 1 545 | 1 245 | | 300 | | 220 |
| ៤_ខេត្តនានា | 64 170 | 64 170 | 63 070 | | 1 100 | | |
| ១៣_ក្រសួងពាណិជ្ជកម្ម | 4 545 | 3 995 | 2 855 | | 1 140 | | 550 |
| ១_ក្រសួង | 3 090 | 2 540 | 1 490 | | 1 050 | | 550 |
| ៤_ខេត្តនានា | 1 455 | 1 455 | 1 365 | | 90 | | |
| ១៤_ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល | 64,270 | 9 770 | 2 125 | | 7 645 | | 57 500 |
| ១_ក្រសួង | 64 720 | 7 220 | 810 | | 6 410 | | 57 500 |
| ៤_ខេត្តនានា | 2 550 | 2 550 | 1 315 | | 1 235 | | |
| ១៥_ក្រសួងផែនការ | 1 765 | 1 655 | 1 625 | | 30 | | 110 |
| ១_ក្រសួង | 800 | 690 | 680 | | 10 | | 110 |
| ៤_ខេត្តនានា | 965 | 965 | 945 | | 20 | | |
| ១៦_ក្រសួងសុខាភិបាល | 62 130 | 36 580 | 35 685 | | 895 | | 25 550 |
| ១_ក្រសួង | 44 410 | 18 860 | 18 040 | | 820 | | 25 550 |
| ៤_ខេត្តនានា | 17 720 | 17 720 | 17 645 | | 75 | | |
| ១៧_ក្រសួងទេសចរណ៍ | 1 790 | 1 415 | 1 310 | | 105 | | 375 |
| ១_ក្រសួង | 1 425 | 1 050 | 955 | | 95 | | 375 |
| ៤_ខេត្តនានា | 365 | 365 | 355 | | 10 | | |
| ១៨_ក្រសួងធម្មការនិង កិច្ចការសាសនា | 1 050 | 1 020 | 975 | | 45 | | 30 |
| ១_ក្រសួង | 510 | 480 | 470 | | 10 | | 30 |
| ៤_ខេត្តនានា | 540 | 540 | 505 | | 35 | | |
| ១៩_ក្រសួងប្រៃសណីយ៍និង ទូរគមនាគមន៍ | 25 180 | 24 630 | 24 525 | | 105 | | 550 |
| ១_ក្រសួង | 24 405 | 23 855 | 23 770 | | 85 | | 550 |
| ៤_ខេត្តនានា | 775 | 775 | 755 | | 20 | | |

# ការគ្រប់គ្រង ឆ្នាំ ១៩៩៥

## តារាង "ខ" - ច្បាប់ហិរញ្ញវត្ថុកែតំរូវ

## ចំណាយថវិកាចរន្តរបស់រដ្ឋ

ការបូកសរុបចំណាយតាមក្រសួងនិងតាមប្រភេទ

ឯកតាគិតជាលានរៀល

| ប្រភេទ / ក្រសួងនានា / ផ្នែក | សរុបចំណាយ | សរុបចំណាយជាប្រចាំ | 1 ប្រភេទទី១: មធ្យោបាយសេវា | 2 ប្រភេទទី២: ការប្រាក់នៃការខ្ចីបុល | 3 ប្រភេទទី៣: អន្តរាគមន៍សាធារណៈ | 4 ប្រភេទទី៤: ចំណាយផ្សេងៗ និង ចំណាយមិនបានគ្រោងទុក | 5 ប្រភេទទី៥: ចំណាយជាមូលធន |
|---|---|---|---|---|---|---|---|
| ២០_ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | 4 960 | 4 665 | 4 530 | | 135 | | 295 |
| ១_ក្រសួង | 3 380 | 3 085 | 2 980 | | 105 | | 295 |
| ៤_ខេត្តនានា | 1 580 | 1 580 | 1 550 | | 30 | | |
| ២១_ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន | 37 735 | 37 385 | 2 740 | | 34 645 | | 350 |
| ១_ក្រសួង | 1 780 | 1 430 | 1 050 | | 380 | | 350 |
| ៤_ខេត្តនានា | 35 955 | 35 955 | 1 690 | | 34 265 | | |
| ២២_ក្រសួងបរិស្ថាន | 2 495 | 2 025 | 1 985 | | 40 | | 470 |
| ១_ក្រសួង | 1 820 | 1 350 | 1 345 | | 5 | | 470 |
| ៤_ខេត្តនានា | 675 | 675 | 640 | | 35 | | |
| ២៣_ក្រសួងអភិវឌ្ឍន៍ជនបទ | 52 330 | 3 070 | 2 975 | | 95 | | 49 260 |
| ១_ក្រសួង | 52 330 | 3 070 | 2 975 | | 95 | | 49 260 |
| ៤_ខេត្តនានា | | | | | | | |
| ២៤_ក្រសួងកិច្ចការនារី | 1 080 | 910 | 795 | | 115 | | 170 |
| ១_ក្រសួង | 720 | 550 | 450 | | 100 | | 170 |
| ៤_ខេត្តនានា | 360 | 360 | 345 | | 15 | | |
| ៩៩_ចំណាយផ្សេងៗនិងពុំបានគ្រោងទុក | 3 800 | 3 800 | | | | 3 800 | |

(១) ក្នុងនោះ: ២ ៧០០ លានរៀល ទាយជូនជាបណ្ដោះអាសន្នត្រូវបែងចែកក្នុងជំពូក៣០

(២) ក្នុងនោះ: ៤ ៥០០ លានរៀល ទាយជូនជាបណ្ដោះអាសន្នត្រូវបែងចែកក្នុងជំពូក៥០ (បរិការសព្វាវុធក្នុងស្រុក)